ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ថ្ងៃព្រហស្បតិ៍ ៤កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមករា ឆ្នាំ២០២៦

## ប្រតិទិនសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦

| ល.រ | ភារកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|---|
| ១ | ការចែកលិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ | ថ្ងៃទី៧ ខែកញ្ញា - ៦ ខែតុលា ឆ្នាំ២០២៦ |
| ២ | ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិ និងអ្នកសារព័ត៌មានជាតិ | ថ្ងៃទី៧ខែកញ្ញា ឆ្នាំ២០២៦-២ ខែកុម្ភៈ ឆ្នាំ២០២៧ |
| ៣ | ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ និងអ្នកសារព័ត៌មានអន្តរជាតិ | ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៦-៩ ខែកុម្ភៈ ឆ្នាំ២០២៧ |
| ៤ | ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ | ថ្ងៃទី៣០ខែកញ្ញា ឆ្នាំ២០២៦-២ខែកុម្ភៈ ឆ្នាំ២០២៧ |
| ៥ | ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត | ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦ |
| ៦ | ការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៥ និងបង្ហោះលើអាសយដ្ឋានវេបរបស់ គ.ជ.ប voterlist.nec.gov.kh និងកម្មវិធីទូរសព្ទឆ្លាត (Mobile App) NEC KH | ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៦ |
| ៧ | ការចាប់ផ្ដើមការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ | ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៦ |
| ៨ | ការបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ | ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦ |
| ៩ | ការប្ដឹងតវ៉ានឹងការបដិសេធការសុំចុះឈ្មោះបោះឆ្នោតទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៣ថ្ងៃ | ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៦ (ថ្ងៃចុងក្រោយ) |
| ១០ | ការដោះស្រាយពាក្យបណ្ដឹងតវ៉ាដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៣ថ្ងៃ | ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៦ (ថ្ងៃចុងក្រោយ) |
| ១១ | ការប្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទៅ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៦ (ថ្ងៃចុងក្រោយ) |
| ១២ | ការដោះស្រាយពាក្យបណ្ដឹងតវ៉ាដោយ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៦ (ថ្ងៃចុងក្រោយ) |
| ១៣ | ការប្ដឹងតវ៉ានឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២៦ (ថ្ងៃចុងក្រោយ) |
| ១៤ | ការដោះស្រាយពាក្យបណ្ដឹងតវ៉ាដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី២ ខែមករា ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ១៥ | ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ទូទាំងប្រទេស | ថ្ងៃទី៣ ខែមករា ឆ្នាំ២០២៧ |
| ១៦ | ការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់លើបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតទៅក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ១៧ | ការដោះស្រាយពាក្យបណ្ដឹងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេល ៣ថ្ងៃ | ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ១៨ | ការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ទៅ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ១៩ | ការដោះស្រាយពាក្យបណ្ដឹងដោយ គ.ជ.ប ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ២០ | ការប្ដឹងតវ៉ា ឬការប្ដឹងជំទាស់នឹងសេចក្ដីសម្រេចរបស់ គ.ជ.ប ទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ថ្ងៃ | ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ២១ | ការដោះស្រាយពាក្យបណ្ដឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ថ្ងៃ | ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៧ (ថ្ងៃចុងក្រោយ) |
| ២២ | ការផ្ដល់សុពលភាព និងការប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការដោយ គ.ជ.ប | ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៧ |



# គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

គ.ជ.ប





# សៀវភៅ
# សម្រាប់
# អ្នកចុះឈ្មោះបោះឆ្នោត



**ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦**

**ចាប់ពីថ្ងៃទី៧ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦**

# ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦




ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ គឺជាដំណើរការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោតប្រចាំឆ្នាំ ស្របតាមគោលការណ៍បញ្ជីបោះឆ្នោតអចិន្ត្រៃយ៍ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីរៀបចំបញ្ជីបោះឆ្នោតសម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៦ ឆ្នាំ២០២៧ និងតាមការកំណត់នៃច្បាប់។

**ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦** មានគោលដៅធានាឱ្យបញ្ជីបោះឆ្នោតមានភាពពេញលេញ ភាពត្រឹមត្រូវ និងបច្ចុប្បន្នភាពប្រកបដោយសុវត្ថិភាព តាមរយៈ៖

- **ការស្រង់ និងលុបឈ្មោះអ្នកបោះឆ្នោត៖**
  - ដែលបានទទួលមរណភាព
  - ដែលត្រូវបានដកហូតសិទ្ធិបោះឆ្នោតជាបណ្តោះអាសន្ន
  - ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ដោយមានឯកសារជាសំអាងត្រឹមត្រូវ និងច្បាស់លាស់។

- **ការចុះឈ្មោះបោះឆ្នោត** ជូនដល់៖
    - ប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ឆ្នាំឡើង គិតដល់ថ្ងៃបោះឆ្នោត ទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩) ដែលមិនទាន់បានចុះឈ្មោះបោះឆ្នោតពីមុនមក
    - ប្រជាពលរដ្ឋដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលក្នុងឃុំ សង្កាត់ថ្មី។
- **ការកែតម្រូវទិន្នន័យជីវប្រវត្តិ** (ប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើត ឬផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោត)។
- **ការធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ** (ថតរូប និងផ្តិតមេដៃ) ចំពោះអ្នកចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧ ដែលមិនធ្លាប់បានធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រក្នុងបញ្ជីបោះឆ្នោតពីមុនមក។



# ពេលវេលា និងទីកន្លែងនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត




ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៦ មានរយៈពេល **៥៥ថ្ងៃ** ដែលប្រព្រឹត្តទៅចាប់ពី**ថ្ងៃទី៧ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦** នៅការិយាល័យចុះឈ្មោះបោះឆ្នោតដែលមានទីតាំងនៅតាមសាលាឃុំ សង្កាត់ ឬ នៅតាមភូមិ មួយចំនួនក្នុងឃុំ សង្កាត់ទូទាំងប្រទេស។

ការិយាល័យចុះឈ្មោះបោះឆ្នោតបើកធ្វើការជារៀងរាល់ថ្ងៃ ទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យ៖

- ពេលព្រឹកចាប់ពីម៉ោង ៧:០០ រហូតដល់ម៉ោង ១១:៣០ នាទីថ្ងៃត្រង់
- ពេលរសៀលចាប់ពីម៉ោង ១៤:០០ រហូតដល់ម៉ោង ១៧:៣០ នាទីល្ងាច។

# លក្ខខណ្ឌចុះឈ្មោះបោះឆ្នោត




ដើម្បីចុះឈ្មោះបោះឆ្នោតបាន ប្រជាពលរដ្ឋទាំងពីរភេទត្រូវបំពេញនូវលក្ខខណ្ឌ ដូចខាងក្រោម៖

- បង្ហាញខ្លួន និងមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) នៅចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោតដែលនៅសាលាឃុំ សង្កាត់ ឬតាមភូមិមួយចំនួន
- មានសញ្ជាតិខ្មែរ
- មានអាយុ ១៨ឆ្នាំឡើង គិតដល់ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៧ (កើតមុន ឬត្រឹមថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៩)
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវចុះឈ្មោះ-បោះឆ្នោត ឬត្រូវបោះឆ្នោត

– មិនទាន់បានចុះឈ្មោះបោះឆ្នោត ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះបោះឆ្នោត នៅកន្លែងណាមួយក្នុងឃុំ សង្កាត់។



១ ត្រូវចាំថា ប្រជាពលរដ្ឋម្នាក់ៗ ត្រូវមានឈ្មោះតែមួយក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតតែមួយគត់។

២ ក្នុងករណីប្រជាពលរដ្ឋណាម្នាក់ ធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមាន បំណងសុំប្តូរការិយាល័យបោះឆ្នោត សូមប្រាប់ប្រធាន ក.ច.ប

៣ យោងតាមមាត្រា ១៤៤ នៃច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ ចំពោះជនណា ដោយទុច្ចរិត ព្យាយាមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយ ត្រូវផាក ពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ដោយ គ.ជ.ប លើកលែងតែមាន ការអនុញ្ញាតដោយច្បាប់។

# ដំណើរប្រព្រឹត្តទៅនៃការចុះឈ្មោះបោះឆ្នោត




នៅពេលបានចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត អ្នកសុំចុះឈ្មោះត្រូវទៅជួបប្រធានក្រុមចុះឈ្មោះបោះឆ្នោតមុនគេ។ ប្រធាន ក.ច.ប នឹងសាកសួរអ្នកនូវព័ត៌មានដូចខាងក្រោម៖

- តើអ្នកមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) [១] ឬទេ?
- តើអ្នកធ្លាប់បានចុះឈ្មោះបោះឆ្នោតឬនៅ?

[១] *ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតគ្មាន អ.ខ ត្រូវស្នើសុំ ឯ.អ ។ (នីតិវិធីនៃការស្នើសុំ ឯ.អ សូមមើលទំព័រទី១៥ និងទំព័រទី១៦)។*




- បន្ទាប់មក ប្រធាន ក.ច.ប ពិនិត្យភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត។




ជំហានទី១ ជួបប្រធាន ក.ច.ប

- ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតបានបំពេញគ្រប់លក្ខខណ្ឌកំណត់ ប្រធាន ក.ច.ប នឹងជម្រាបឱ្យអ្នកសុំចុះឈ្មោះបោះឆ្នោតទៅជួបអនុប្រធាន ក.ច.ប ដែលនៅអង្គុយតុជាប់គ្នា។

- បន្ទាប់មក អនុប្រធាន ក.ច.ប សួរអ្នកសុំចុះឈ្មោះអំពីទីលំនៅក្នុងភូមិណា ដើម្បីគាត់កំណត់បញ្ចូលឈ្មោះទៅក្នុងការិយាល័យបោះឆ្នោតនៃភូមិនោះ។



ជំហានទី២ ជួបអនុប្រធាន ក.ច.ប






អនុប្រធាន ក.ច.ប បំពេញទម្រង់បង្កាន់ដៃ ទ.១០២២ មានអត្តលេខ



ការីកុំព្យូទ័របញ្ចូលទិន្នន័យអ្នកសុំចុះឈ្មោះ
បោះឆ្នោតទៅក្នុងកម្មវិធីកុំព្យូទ័រ ផ្អែកតាម អ.ខ ឬ ឯ.អ និងតាមបង្កាន់ដៃបញ្ជាក់
ការចុះឈ្មោះបោះឆ្នោត (ទ.១០២២)។ ជាដំបូង បញ្ចូលព័ត៌មានការិយាល័យបោះឆ្នោត
បន្ទាប់មក ធ្វើតេស្តស្នាមមេដៃទាំងសងខាងរបស់អ្នកសុំចុះឈ្មោះបោះឆ្នោត។




ជំហានទី៣ ជួបការីកុំព្យូទ័រ



ការីកុំព្យូទ័រថតអ.ខ ឬ ឯ.អ និងបញ្ចូលឈ្មោះ និងទិន្នន័យ
របស់អ្នកសុំចុះឈ្មោះបោះឆ្នោតចូលទៅក្នុងកម្មវិធីកុំព្យូទ័រ។




ការីកុំព្យូទ័រថត អ.ខ របស់អ្នកសុំចុះឈ្មោះបោះឆ្នោត






ការីកុំព្យូទ័រថតរូបអ្នកសុំចុះឈ្មោះបោះឆ្នោត






ការីកុំព្យូទ័រផ្ដិតយកស្នាមមេដៃអ្នកសុំចុះឈ្មោះបោះឆ្នោត



បន្ទាប់មក ការីកុំព្យូទ័រប្រាប់អ្នកសុំចុះឈ្មោះ-
បោះឆ្នោតឱ្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួន
ដែលបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២។




អ្នកសុំចុះឈ្មោះបោះឆ្នោតផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួន ដែលបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២



ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមិនចេះអក្សរ ឬមើលមិនច្បាស់ គាត់អាចស្នើសុំជំនួយពីអ្នកដទៃបាន ដើម្បីផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់គាត់។

ចុងក្រោយ ភារីកុំព្យូទ័រប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និង អ.ខ ឬ ឯ.អ ជូនអ្នកសុំចុះឈ្មោះបោះឆ្នោត ជាការស្រេច។




ភារីកុំព្យូទ័រប្រគល់បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) និង អ.ខ ឬ ឯ.អ


១
ឃើញទេ!
ការចុះឈ្មោះបោះឆ្នោតតាមកម្មវិធីកុំព្យូទ័រ
មិនចំណាយពេលយូរទេ។
២
អូ!ពិតជាងាយស្រួលណាស់!
អ៊ីចឹងខ្ញុំប្រញាប់ទៅចុះឈ្មោះ-
បោះឆ្នោតនឹងគេដែរសិន។

# ឯកសារសម្រាប់ប្រើប្រាស់ក្នុងការចុះឈ្មោះបោះឆ្នោត

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ដែលមានសុពលភាព









ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត (ឯ.អ) ចេញដោយអាជ្ញាធរឃុំ សង្កាត់





ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Nº XXXXXXX

រាជធានី ខេត្ត ....................
ក្រុង ស្រុក ខណ្ឌ ...............
ឃុំ សង្កាត់ ......................
លេខ ..............................

ឯកសារបញ្ជាក់អត្តសញ្ញាណ
បម្រើឱ្យការចុះឈ្មោះបោះឆ្នោត

យោងលិខិតស្នើសុំរបស់សាមីខ្លួនចុះថ្ងៃទី..........ខែ.........ឆ្នាំ២០..........
យើងមេឃុំ ចៅសង្កាត់ ☐ ជំទប់/ចៅសង្កាត់រងទទួលសិទ្ធិ ☐ ..........................
ចេញឯកសារបញ្ជាក់អត្តសញ្ញាណឱ្យឈ្មោះ..............................ភេទ..........សញ្ជាតិ..............
កើតនៅថ្ងៃទី..........ខែ..........ឆ្នាំ..........មានលំនៅឋានផ្ទះលេខ............ផ្លូវ............ភូមិ..............
ក្នុងឃុំ សង្កាត់នេះ ប្រើប្រាស់សម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ ។

....................ថ្ងៃទី......... ខែ......... ឆ្នាំ២០......
ហត្ថលេខា ឈ្មោះ និងត្រាឃុំ សង្កាត់

# ករណីគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ)




ប្រសិនបើប្រជាពលរដ្ឋគ្មាន អ.ខ សាមីខ្លួនត្រូវស្នើសុំ ឯ.អ ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត (ចាប់ពីថ្ងៃទី៧ ខែតុលា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៦) ដោយត្រូវមកបង្ហាញខ្លួនផ្ទាល់ចំពោះមុខមេឃុំ ឬចៅសង្កាត់ ដើម្បីបំពេញពាក្យស្នើសុំ និងនាំមកនូវ៖



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

N° XXXXXXX

រាជធានី ខេត្ត ....................
ក្រុង ស្រុក ខណ្ឌ ................
ឃុំ,សង្កាត់ ........................
លេខ ..............................

ឯកសារបញ្ជាក់អត្តសញ្ញាណ
បម្រើឱ្យការចុះឈ្មោះបោះឆ្នោត

យោងលិខិតស្នើសុំរបស់សាមីខ្លួនចុះថ្ងៃទី...........ខែ.........ឆ្នាំ២០.......
យើងមេឃុំ ចៅសង្កាត់ ☐ ជំទប់/ចៅសង្កាត់រងទទួលសិទ្ធិ ☐ ..................................
ចេញឯកសារបញ្ជាក់អត្តសញ្ញាណឱ្យឈ្មោះ..................................ភេទ..........សញ្ជាតិ..............
កើតនៅថ្ងៃទី..........ខែ.........ឆ្នាំ...........មានលំនៅឋានផ្ទះលេខ............ផ្លូវ............ភូមិ................
ក្នុងឃុំ សង្កាត់នេះ ប្រើប្រាស់សម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ ។

...................ថ្ងៃទី......... ខែ......... ឆ្នាំ២០.......
ហត្ថលេខា ឈ្មោះ និងត្រាឃុំ សង្កាត់

- សំបុត្រកំណើតច្បាប់ដើម ឬសេចក្ដីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ឬព្រះរាជក្រឹត្យ ឬសេចក្ដីចម្លងព្រះរាជក្រឹត្យផ្ដល់សញ្ជាតិខ្មែរ ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថាសាមីខ្លួននោះកើតពីឪពុក ឬម្ដាយដែលមានសញ្ជាតិខ្មែរ
- សាក្សី ២ (ពីរ) រូប ដែលមានសិទ្ធិបោះឆ្នោត និងមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ជាមួយអ្នកស្នើសុំ
- រូបថត ៣ x ៤ ចំនួន ២ (ពីរ) សន្លឹក។



# ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមាន អ.ខ ប៉ុន្តែពុំមាន លក្ខខណ្ឌគ្រប់គ្រាន់







\+




ឬ








ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត..........
ក្រុង ស្រុក ខណ្ឌ..........
ឃុំ សង្កាត់..........

លេខ: 000000000

**លិខិតបញ្ជាក់ទីលំនៅ**

យោងប្រកាសលេខ..... ប្រ.ក ចុះថ្ងៃទី.... ខែ...... ឆ្នាំ២០១... របស់ក្រសួងមហាផ្ទៃ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត។

យើងមេឃុំ ចៅសង្កាត់__________សូមបញ្ជាក់ថា៖
- ឈ្មោះ:__________ភេទប្រុស ☐ ស្រី ☐
- កើតនៅថ្ងៃ____ទីខែ____ឆ្នាំ____ ពិតជាមានលំនៅឋានឬទីសំណាក់
- លេខ____ផ្លូវ____ភូមិ____ឃុំ សង្កាត់____
ក្រុង ស្រុក ខណ្ឌ____រាជធានី ខេត្ត____ពិតប្រាកដមែន។

លិខិតបញ្ជាក់ទីលំនៅនេះធ្វើឡើងដោយផ្អែកលើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដែលមានលេខ__________និងការឆ្លើយបញ្ជាក់របស់សាមីខ្លួន និងសាក្សី៖
- ឈ្មោះ:__________ភេទប្រុស ☐ ស្រី ☐
- កើតនៅថ្ងៃទី____ខែ____ឆ្នាំ____មានលំនៅឋានឬទីសំណាក់
លេខ____ផ្លូវ____ភូមិ____ឃុំ សង្កាត់____
ក្រុង ស្រុក ខណ្ឌ____រាជធានី ខេត្ត____
ពិតជាត្រឹមត្រូវ និងទទួលខុសត្រូវចំពោះមុខច្បាប់ ។

លិខិតបញ្ជាក់ទីលំនៅនេះ ចេញជូនសាមីខ្លួន សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោតតាមការកំណត់នៃច្បាប់បោះឆ្នោត។

ធ្វើនៅថ្ងៃទី..........ខែ..........ឆ្នាំ..........

ស្នាមមេដៃ　　　　មេឃុំ ចៅសង្កាត់

សាមីខ្លួន　　　　សាក្សី

ប្រកាសរបស់ក្រសួងមហាផ្ទៃ ស្ដីពីនីតិវិធី និងបែបបទនៃការចេញលិខិតបញ្ជាក់ទីលំនៅក្នុងឃុំ សង្កាត់ ដោយអាជ្ញាធរឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ សម្រាប់គោលដៅនៃការចុះឈ្មោះបោះឆ្នោត បានកំណត់ថា អាជ្ញាធរឃុំ សង្កាត់ជាអ្នកចេញលិខិតបញ្ជាក់ទីលំនៅ។

ដើម្បីទទួលបានលិខិតបញ្ជាក់ទីលំនៅពីអាជ្ញាធរឃុំ សង្កាត់ ប្រជាពលរដ្ឋខ្មែរត្រូវទៅបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខមេឃុំ ឬចៅសង្កាត់ដែលសាមីខ្លួនមានលំនៅឋាន ឬទីសំណាក់ដែលត្រូវចុះឈ្មោះបោះឆ្នោត។ នៅក្នុងពេលទៅបង្ហាញខ្លួន ប្រជាពលរដ្ឋខ្មែរត្រូវនាំទៅជាមួយនូវ ៖

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរដែលមានសុពលភាព
- លិខិតអនុញ្ញាតឱ្យស្នាក់នៅបណ្ដោះអាសន្ន (ក៩) [២] ចេញដោយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់របស់សាមីខ្លួន និង
- សាក្សី ១ (មួយ) រូប ដែលមានសិទ្ធិបោះឆ្នោតនៅឃុំ សង្កាត់ជាមួយ
- សាក្សីត្រូវនាំយកទៅជាមួយនូវឯកសារផ្លូវការដែលមានចុះអំពីលំនៅឋាន ឬទីសំណាក់របស់សាក្សីនោះ។

---

[២] *សូមបញ្ជាក់ថា ដើម្បីបានលិខិតអនុញ្ញាតឱ្យស្នាក់នៅបណ្ដោះអាសន្ន (ក៩) នេះ គឺប្រជាពលរដ្ឋខ្មែរដែលបានស្នាក់អាស្រ័យនៅ ឬអាស្រ័យនៅយ៉ាងតិច ៣០(សាមសិប) ថ្ងៃ ក្នុងឃុំ សង្កាត់ និងត្រូវចុះបញ្ជីស្នាក់នៅបណ្ដោះអាសន្ន (ក៨) ។*

# ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមានបំណងកែតម្រូវទិន្នន័យជីវប្រវត្តិ ឬទិន្នន័យជីវមាត្រ ក្នុងបញ្ជីបោះឆ្នោត

## ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំប្តូរការិយាល័យបោះឆ្នោត




ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយ តែមានបំណងស្នើសុំប្តូរការិយាល័យបោះឆ្នោតពីភូមិមួយទៅភូមិមួយទៀតក្នុងឃុំ សង្កាត់ដដែលដោយសារបានផ្លាស់ប្តូរទីលំនៅ ឬស្នើសុំប្តូរពីការិយាល័យបោះឆ្នោតមួយទៅការិយាល័យបោះឆ្នោតមួយទៀតក្នុងភូមិជាមួយ ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម៖

– ចាត់ឱ្យអនុប្រធាន ក.ច.បៈ

- បំពេញទម្រង់បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ចុះហត្ថលេខា ឈ្មោះ បោះត្រាការិយាល័យចុះឈ្មោះបោះឆ្នោត និងបោះត្រាបន្ថែមនៅលើទម្រង់នេះរវាងគល់ទម្រង់ និងបង្កាន់ដៃ
- ហែកបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ប្រគល់ជូនការីកុំព្យូទ័រ
- ដកហូតបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត (ទ.១០២២) ចាស់ (ប្រសិនបើមាន) កិបភ្ជាប់ជាមួយគល់បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ដែលត្រូវបញ្ជូនមក គ.ជ.ប
- ណែនាំអ្នកស្នើសុំនោះឱ្យទៅជួបការីកុំព្យូទ័រ។

– ចាត់ឱ្យការីកុំព្យូទ័រៈ

- ទាញយកទិន្នន័យរបស់អ្នកស្នើសុំតាមរយៈស្នាមមេដៃ អត្តលេខ លេខ អ.ខ ឬលេខ ឯ.អ ឬនាមត្រកូល និងនាមខ្លួន។ ប្រសិនបើមានទិន្នន័យបង្ហាញថាជារបស់អ្នកស្នើសុំពិតប្រាកដ ការីកុំព្យូទ័រត្រូវផ្ទេរឈ្មោះ និងទិន្នន័យអ្នកស្នើសុំប្តូរការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ទៅការិយាល័យបោះឆ្នោតថ្មីក្នុងភូមិដែលគាត់រស់នៅដូចបានកំណត់ក្នុងបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨)
- ជម្រាបអ្នកស្នើសុំឱ្យផ្ទៀងផ្ទាត់ទិន្នន័យរបស់ខ្លួន ដែលបានបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២ រួចស្នើអ្នកស្នើសុំផ្តល់ស្នាមមេដៃ ដើម្បីបញ្ជាក់ថាគាត់ពិតជាបានស្នើសុំប្តូរការិយាល័យបោះឆ្នោត។ ក្នុងករណីអ្នកស្នើសុំមិនអាចផ្តល់ស្នាមម្រាមដៃបានទេ ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិដើម្បីរក្សាទុកទិន្នន័យ

- ប្រគល់បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) និងឯកសារពាក់ព័ន្ធឱ្យអ្នកស្នើសុំ។

# ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំកែតម្រូវទិន្នន័យ ឬ/និងផ្លាស់ប្តូរឯកសារចុះឈ្មោះបោះឆ្នោត




ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឃុំ សង្កាត់នេះ ប៉ុន្តែទិន្នន័យរបស់ខ្លួនដូចជាឈ្មោះ ភេទ ថ្ងៃខែឆ្នាំកំណើតកត់ត្រាមិនត្រឹមត្រូវ ឬទើបបានទទួល អ.ខ ដែលមានសុពលភាព ប្រធាន ក.ច.ប ត្រូវចាត់ចែងដូចខាងក្រោម៖

- ចាត់ឱ្យអនុប្រធាន ក.ច.ប បំពេញបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ជូនសាមីអ្នកស្នើសុំ។ បន្ទាប់មកត្រូវប្រគល់ អ.ខ ឬ ឯ.អ ទៅការីកុំព្យូទ័រ និងណែនាំអ្នកស្នើសុំនោះឱ្យទៅជួបការីកុំព្យូទ័រ។
- ចាត់ឱ្យការីកុំព្យូទ័រឱ្យអនុវត្តដូចខាងក្រោម៖

- ទាញយកឈ្មោះ និងទិន្នន័យរបស់អ្នកស្នើសុំតាមរយៈស្នាមមេដៃ អត្តលេខអ្នកបោះឆ្នោត លេខ អ.ខ លេខ ឯ.អ ឬនាមត្រកូល និងនាមខ្លួន។ ប្រសិនបើទិន្នន័យបង្ហាញថាជារបស់សាមីអ្នកស្នើសុំពិតប្រាកដ ការីកុំព្យូទ័រត្រូវធ្វើការកែតម្រូវទិន្នន័យតាមការស្នើសុំដោយផ្អែកលើ អ.ខ ឬ ឯ.អ ដែលបានប្រើពេលចុះឈ្មោះបោះឆ្នោតពីមុនដែលត្រឹមត្រូវ ថតរូប និងស្កេនស្នាមម្រាមដៃ។ ប្រសិនបើស្នើសុំប្តូរ អ.ខ ការីកុំព្យូទ័រត្រូវថត អ.ខ និងបញ្ចូលលេខ អ.ខ បន្ថែមទៀតទៅក្នុងកម្មវិធីកុំព្យូទ័រ
- ជម្រាបអ្នកស្នើសុំកែតម្រូវឱ្យផ្ទៀងផ្ទាត់ឈ្មោះ ឬ/និងទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើឧបទស្សន៍កុំព្យូទ័រទី២ រួចស្នើអ្នកស្នើសុំផ្តល់ស្នាមម្រាមដៃបញ្ចូលក្នុងកម្មវិធីកុំព្យូទ័រ ដើម្បីបញ្ជាក់ថាគាត់ពិតជាបានស្នើសុំកែតម្រូវទិន្នន័យប្រាកដមែន។ ក្នុងករណីអ្នកស្នើសុំមិនអាចផ្តល់ស្នាមម្រាមដៃបានទេ ប្រធាន ក.ច.ប ត្រូវផ្តល់សិទ្ធិសម្រាប់រក្សាទុកឈ្មោះ ឬ/និងទិន្នន័យដែលបានកែតម្រូវ
- ប្រគល់បង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ឱ្យអ្នកស្នើសុំ។

# ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតស្នើសុំធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្រ
# (ថតរូប និងផ្តិតមេដៃ)






ចំពោះការអនុវត្តវិញ ប្រសិនបើអ្នកសុំចុះឈ្មោះបោះឆ្នោតធ្លាប់បានចុះឈ្មោះបោះឆ្នោតរួចហើយក្នុងឃុំ សង្កាត់នេះ ប៉ុន្តែទិន្នន័យជីវមាត្រ (រូបថត និងស្នាមម្រាមដៃ) របស់ខ្លួនក្នុងបញ្ជីបោះឆ្នោតពុំធ្លាប់បានធ្វើបច្ចុប្បន្នភាពក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ ប្រធាន ក.ច.ប ត្រូវចាត់ចែង៖

- ចាត់ឱ្យអនុប្រធាន ក.ច.ប បំពេញបង្កាន់ដៃប្តូរការិយាល័យក្នុងឃុំ សង្កាត់ ឬ/និងកែតម្រូវទិន្នន័យ (ទ.១០២៨) ជូនសាមីអ្នកស្នើសុំ។ បន្ទាប់មកត្រូវប្រគល់ អ.ខ[៣] ទៅការីកុំព្យូទ័រ និងណែនាំអ្នកស្នើសុំនោះឱ្យទៅជួបការីកុំព្យូទ័រ
- ចាត់ការីកុំព្យូទ័រថតរូប និងស្កេនស្នាមម្រាមដៃអ្នកស្នើសុំឡើងវិញជាការស្រេច។

[៣] *សូមបញ្ជាក់ថា សាមីអ្នកស្នើសុំ ក៏អាចប្រើប្រាស់ អ.ខ អស់សុពលភាព មកធ្វើបច្ចុប្បន្នភាពទិន្នន័យជីវមាត្របានដែរ។*

# ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោត ដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត




គ.ជ.ប នឹងបិទផ្សាយជាសាធារណៈនូវ**បញ្ជីបោះឆ្នោតដំបូង ព្រមទាំងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជី បោះឆ្នោត នៅថ្ងៃទី៣ ខែមករា ឆ្នាំ២០២៧** នៅសាលាឃុំ សង្កាត់ និងនៅទីប្រជុំជនណាមួយក្នុងឃុំ សង្កាត់។ ខាងក្រោមនេះ គឺជាគំរូបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត៖


បញ្ជីបោះឆ្នោតដំបូងឆ្នាំ២០២៦

បញ្ជីបោះឆ្នោតដំបូង



បញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត

ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត មានគោលបំណងឱ្យប្រជាពលរដ្ឋអញ្ជើញទៅពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យផ្សេងៗរបស់គាត់ ព្រមទាំងមានសិទ្ធិអាចធ្វើការប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់លើបញ្ជីទាំងពីរនេះបាន។



# ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការ




គ.ជ.ប ត្រូវផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការ នៅ **ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៧**។

គ.ជ.ប នឹងបញ្ជូនបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២៦ ទៅសាលាឃុំ សង្កាត់ ១ (មួយ) ច្បាប់ និងទៅលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) ១ (មួយ) ច្បាប់ ដើម្បីរក្សាទុកជាឯកសារផ្លូវការ។




សូមចងចាំថា
ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត
ផ្លូវការឆ្នាំ២០២៦ ទើបមានសិទ្ធិបោះឆ្នោតជ្រើសរើស
ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៦ ឆ្នាំ២០២៧ បាន។
ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
អាណត្តិទី៦ នឹងប្រព្រឹត្តទៅនាថ្ងៃអាទិត្យ ទី៦
ខែមិថុនា ឆ្នាំ២០២៧ ខាងមុខ។